**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០២

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៣៦២ សហវ.ប្រក.

# ប្រកាស

## ស្តីពី

## ការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខនស/ រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦ /១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០២ លើសំណើលេខ ១២៩១ សហវ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : បង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ក្រុង ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការិយាល័យកណ្តាលបោះប្រចាំនៅទីចាត់ការគយនិងរដ្ឋាករ ។

**ប្រការ ២** : សាខាគយនិងរដ្ឋាកររាជធានីភ្នំពេញដឹកនាំដោយប្រធានសាខាមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

ប្រការ ៣ : សាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ មានភារកិច្ចដូចតទៅ ៖

១- គ្រប់គ្រង ដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់ លើបណ្ដាទីស្នាក់ការគយនិងរដ្ឋាករប្រចាំតាមបណ្ដាខណ្ឌ ស្រុក នីមួយៗនៃរាជធានីភ្នំពេញ ។

២- ចាត់ចែង រៀបចំ ផ្សព្វផ្សាយតាមរូបភាពនានាដល់អាជីវករ និងបុគ្គលពាក់ព័ន្ធទាំងឡាយឱ្យយល់ដឹងទាន់ពេលវេលាពីភាពស្របច្បាប់នៃទំនិញនាំចូល និងការទទួលខុសត្រូវចំពោះមុខច្បាប់ រាល់ពេលរកឃើញមានការចូលរួមគេចវេសការគព្វកិច្ចពន្ធ អាករដោយផ្ទាល់ ឬ ដោយប្រយោល ការធ្វើចរាចរចែកចាយសន្និធិទំនិញនាំចូលដោយល្មើសនានាក្នុងមូលដ្ឋាន អាជីវកម្មដ្ឋាន ឬ លំនៅដ្ឋាននីមួយៗ ។

៣- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់រាជធានីភ្នំពេញ លើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬ កំពុងប្រើប្រាស់តាមបណ្ដាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬ លំនៅដ្ឋាននានា ដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

៤- ចុះស្រង់ និងកសាងបញ្ជីជំរឿនស្ថិតិ អាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញនានា ដែលស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងពិសេស រួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលគេលសិលា ភេសជ្ជៈ ព្រមទាំងទំនិញរសើបមួយចំនួនទៀតដែលនឹងកំណត់ដោយទីចាត់ការគយនិងរដ្ឋាករ ។

៥- អនុវត្តតាមភារកិច្ចផ្សេងៗដែលនឹងកំណត់តាមការចាំបាច់នានា ដោយទីចាត់ការគយនិងរដ្ឋាករស្របតាមបញ្ញត្តិច្បាប់ជាធរមាន ។

៦- ប្រើប្រាស់កំលាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រចាំមូលដ្ឋាន ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសំរេចឱ្យបាននូវភារកិច្ចដូចរៀបរាប់ខាងលើ ។

ប្រការ ៤ : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- សាលាក្រុងភ្នំពេញ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ( ដើម្បីសហការអនុវត្ត )
- ដូចប្រការ៥ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ